ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

vhs DVV International

# សៀវភៅណែនាំស្តីពីការដឹកនាំ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត



ផលិតដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
ខែកុម្ភៈ ឆ្នាំ២០១៧

ឧបត្ថម្ភដោយ:

សហភាពអឺរ៉ុប

BMZ Federal Ministry for Economic Cooperation and Development

# តារាងមាតិកា


គោលបំណងនៃសៀវភៅណែនាំ ....... ៤

I. សារតា ....... ៥

តើបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត (P-ESWG) គឺជាអ្វី? ....... ៥

តើក្រុមការងារវិស័យអប់រំថ្នាក់ខេត្តត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច? ....... ៥

ស្ថានភាពបច្ចុប្បន្ននៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តចាប់តាំងពីការបង្កើតដំបូង ....... ៧

II. ទស្សនៈវិស័យ / បេសកកម្ម ....... ៨

ទស្សនៈវិស័យ ....... ៨

បេសកកម្ម ....... ៨

III. ការបង្កើតបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ....... ៨

១. រចនាសម្ព័ន្ធរបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ....... ៨

**២. និតិវិធីក្នុងការបង្កើតបណ្តាញក្រុមការងារ** ....... ៩

**៣. អាណត្តិរបស់ប្រធាន អនុប្រធាន និងលេខាធិការ** ....... ១១

**៤. តួនាទីនិងការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន និងលេខាធិការ** ....... ១១

៥. ការទទួលខុសត្រូវចម្បងរបស់សមាជិកបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ....... ១៣

៦. ការទទួលស្គាល់ពីក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ ....... ១៣

IV. ដំណើរការរបស់ក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ....... ១៣

១. រៀបចំលក្ខខណ្ឌយោង (TOR) ....... ១៣

២. រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ....... ១៤

៣. រៀបចំការប្រជុំប្រចាំត្រីមាស ....... ១៤

៤. ការតស៊ូមតិ ....... ១៥

៥. ការកសាងសមត្ថភាពសម្រាប់ថ្នាក់ដឹកនាំបណ្តាញ ....... ១៦

៦. ធានាឱ្យការទំនាក់ទំនងមានប្រសិទ្ធិភាព ....... ១៦

៧. ធ្វើរបាយការណ៍ ....... ១៧

៨. ការទទួលស្គាល់ការងាររបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ....... ១៧

V. វិធីសាស្ត្រខ្លះសម្រាប់ថ្នាក់ដឹកនាំ (ប្រធាន អនុប្រធាន និងលេខាធិការបណ្តាញ) ....... ១៧

១. សម្របសម្រួលកិច្ចប្រជុំ ....... ១៧

២. ការតម្រង់ទិសនិងការផ្ទេរតំណែងសម្រាប់ប្រធាន/អនុប្រធានថ្មី ....... ១៩

ឧបសម្ព័ន្ធនិងទម្រង់ផ្សេងៗ ....... ២១

# សេចក្ដីផ្ដើម

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការ Deutscher Volkshochschul-Verbandese.V. (DVV) អន្តរជាតិដោយមានការគាំទ្រមូលនិធិពីសហភាពអឺរ៉ុប និងក្រសួងអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការអាល្លឺម៉ង់(BMZ) កំពុងអនុវត្តគម្រោង“ *កៀរគរសង្គមស៊ីវិលក្នុងការដោះស្រាយភាពខ្វះចន្លោះនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ”* ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសេវាអប់រំនៅប្រទេសកម្ពុជា តាមរយៈការចូលរួមកាន់តែខ្លាំងរបស់សង្គមស៊ីវិលនៅក្នុងកិច្ចពិភាក្សា តាមដានការអនុវត្តគោលនយោបាយនានា និងការតស៊ូមតិរួមគ្នា។ គម្រោងនេះ ចាប់អនុវត្តពីខែមករាឆ្នាំ២០១៦ ដល់ខែធ្នូឆ្នាំ២០១៨ នឹងផ្ដល់ឱកាសក្នុងការជំរុញការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងគោលនយោបាយរដ្ឋាភិបាល និងពង្រឹងយន្តការអង្គការសង្គមស៊ីវិលក្នុងន័យជានានិរន្តរភាព។

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល គឺជាអង្គការដឹកនាំអនុវត្តគម្រោងក្នុងភាពជាដៃគូនេះ ដោយមានជាតុចូលបន្ថែមទៀតផ្ដល់ដោយអង្គការ DVV អន្តរជាតិ និងសកម្មភាពមួយចំនួននៃគម្រោងនឹងត្រូវអនុវត្តដោយអ្នកផ្ដល់សេវាខាងក្រៅ ឬតាមរយៈគម្រោងជំនួយខ្នាតតូច។ គម្រោងនេះមានគោលបំណងដើម្បីកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលដែលធ្វើការនៅក្នុងប្រទេសកម្ពុជា ជាពិសេសលើវិស័យអប់រំ ដើម្បីចូលរួមឱ្យបានពេញលេញ និងមានប្រសិទ្ធិភាពជាងមុនក្នុងការសម្រេចចិត្តនិងអភិបាលកិច្ចមូលដ្ឋាន ហើយជំរុញគោលនយោបាយថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ ដើម្បីពង្រឹងសមភាពនិងបរិយាប័ន្ននៃការផ្ដល់សេវាអប់រំ ហើយឆ្លើយតបយ៉ាងមានទំនុកចិត្តទៅនឹងការពង្រឹងគណនេយ្យភាពមូលដ្ឋាន។

សកម្មភាពសំខាន់ៗនៃគម្រោងនេះ គឺពង្រឹងបណ្ដាញថ្នាក់ក្រោមជាតិ (បណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត) នៅក្នុងខេត្តនីមួយដោយផ្ដល់នូវការគាំទ្រ ការបណ្ដុះបណ្ដាដល់តំណាងនិងសមាជិកបបណ្ដាញក្រុមការងារ។ ការងារនេះអាចសម្រេចបានតាមរយៈការបង្កើតសៀវភៅណែនាំស្ដីពីការដឹកនាំបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ដែលហៅកាត់ជាភាសាអង់គ្លេស *“P-ESWG handbook”*។

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) បានគាំទ្របណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ហើយបណ្ដាញក្រុមការងារនៅតាមខេត្តភាគច្រើន (២២ ក្នុងចំណោម២៥) កំពុងដំណើរការ។ បណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តត្រូវបានបង្កើតឡើងដោយមានអង្គការសង្គមស៊ីវិលដែលសកម្មនៅក្នុងវិស័យអប់រំនៅក្នុងខេត្តផ្ទាល់ និងបានធ្វើការដោយផ្ទាល់ជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ទោះជាយ៉ាងណាក៏ដោយ តំណាងបណ្ដាញក្រុម

ការងារ (ប្រធាន និងអនុប្រធាន)ដែលត្រូវបានជ្រើសរើសដោយសមាជិកតាមរយៈការបោះឆ្នោតកំពុងប្រឈមនឹងបញ្ហាសមត្ថភាព។ ដូច្នេះ ដើម្បីគាំទ្រដល់តំណាងបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តក្នុងការដឹកនាំបណ្ដាញឱ្យមានប្រសិទ្ធិភាព គម្រោងដែលផ្ដល់មូលនិធិគាំទ្រពីសហភាពអឺរ៉ុបនេះនឹងផលិតសៀវភៅណែនាំស្ដីពីការដឹកនាំបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តដោយរួមមានការអនុវត្តល្អៗ លក្ខខណ្ឌយោង និងតួនាទីផ្សេងៗរបស់ថ្នាក់ដឹកនាំបណ្ដាញក្រុមការងារ។

## គោលបំណងនៃសៀវភៅណែនាំ

សៀវភៅណែនាំស្ដីពីការដឹកនាំបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត មានគោលបំណងជួយឱ្យតំណាងនិងសមាជិកបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តយល់ពីរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធនីមួយៗ (ឧទាហរណ៍ ប្រធាន អនុប្រធាន លេខានិងសមាជិក) ដូច្នេះអ្នកពាក់ព័ន្ធទាំងអស់អាចធ្វើការសហការគ្នាដើម្បីសម្រេចគោលដៅរួម។

# I. សាវតា

## តើបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត (P-ESWG)គឺជាអ្វី?

បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត រួមមានអង្គការសង្គមស៊ីវិល (អង្គការក្នុងស្រុក និងអន្តរជាតិមិនមែនរដ្ឋាភិបាល)ដែលសកម្មនៅក្នុងវិស័យអប់រំនិងមានគោលបំណងធ្វើការរួមគ្នាក្នុងការនាំយកការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងគោលនយោបាយអប់រំ និងការអនុវត្តនានា តាមរយៈការធ្វើការរួមគ្នា ការផ្សារភ្ជាប់គ្នាទៅវិញទៅមក ចែករំលែកព័ត៌មាន រួមគ្នាត្រួតពិនិត្យការផ្តល់សេវាអប់រំ និងធ្វើការតស៊ូមតិនិងពិភាក្សាគោលនយោបាយរួមគ្នានៅថ្នាក់ខេត្ត។

## តើក្រុមការងារវិស័យអប់រំថ្នាក់ខេត្តត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច?

នៅដើមឆ្នាំ២០០០ អង្គការមិនមែនរដ្ឋាភិបាលនានាដែលផ្តោតលើវិស័យអប់រំធ្វើការដាច់ដោយឡែកៗពីគ្នា ជាមួយវិធីសាស្រ្តផ្សេងៗគ្នាក្នុងការតស៊ូមតិ។ យើងកត់សម្គាល់ឃើញថាក្រសួងអប់រំយុវជននិងកីឡាជួបការលំបាកក្នុងការរកអ្នកតំណាងសង្គមស៊ីវិលមួយ ដើម្បីចូលរួមក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ[1] (JTWG-ED) ។ រដ្ឋមន្ត្រីក្រសួងអប់រំបានរកឃើញវិធីសាស្រ្តមួយ ដើម្បីរកអ្នកតំណាងម្នាក់នៃសង្គមស៊ីវិលដែលអាចតំណាងឱ្យសំឡេងរបស់អង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដែលធ្វើការនៅកម្ពុជា ដើម្បីចូលរួមវេទិកាសំខាន់នេះសម្រាប់កិច្ចសន្ទនានិងការពិភាក្សានានា ក្នុងន័យស្ថាបនាដើម្បីសម្រេចបាននូវគោលបំណងនៃកំណែទម្រង់វិស័យអប់រំ។

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២និងបានក្លាយជាតំណាងឱ្យសំឡេងនៃអង្គការមិនមែនរដ្ឋាភិបាលទាំងអស់នៅក្នុងវិស័យអប់រំ ដោយសារអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ជាអង្គការសមាជិកភាពតែមួយគត់សម្រាប់អង្គការសង្គមស៊ីវិលដែលផ្តោតលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិប្រមាណជាង១៣០អង្គការដែលធ្វើការនៅគ្រប់ខេត្តក្រុងនៅក្នុងប្រទេស។ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល បានផ្តល់ជាតុចូលដ៏មានតម្លៃជាច្រើនៗលើកំណែទម្រង់វិស័យអប់រំក្នុងនាមអង្គការមិនមែនរដ្ឋាភិបាលនានានៅក្នុងវិស័យនេះ តាមរយៈការខិតខំសិក្សាស្រាវជ្រាវរបស់ខ្លួន

---

[1] ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិមានសមាសភាពជា សមាជិករាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ តំណាងសង្គមស៊ីវិល។ គោលបំណងរួមនៃក្រុមការងារបច្ចេកទេសគឺលើកកម្ពស់ប្រសិទ្ធភាពជំនួយនិងភាពជាដៃគូអភិវឌ្ឍន៍ក្នុងការគាំទ្រការសម្រេចបានសមិទ្ធិផលផែនការវិស័យអប់រំនិងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំយុវជននិងកីឡា (អយក)។

និងពិនិត្យឡើងវិញលើឯកសារគោលនយោបាយរបស់រដ្ឋាភិបាល។ លើសពីនេះទៅទៀត អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលទទួលបានការកត់សម្គាល់យ៉ាងខ្លាំងក្នុងការតស៊ូមតិដើម្បីកាអភិវឌ្ឍគោលនយោបាយអប់រំប្រកបដោយបរិយាប័ន្ន សម្រាប់ជនក្រីក្រ ដោយផ្អែកលើការស្រាវជ្រាវ និងការវិភាគស៊ីជម្រៅ។

ដូច្នេះ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ត្រូវបានតែងតាំងឱ្យធ្វើជាតំណាងអង្គការសង្គមស៊ីវិលនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ ក្រោយមកត្រូវបានទទួលស្គាល់ដោយឯកឧត្តមកុល ផេង ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ជាដៃគូផ្លូវការតំណាងឱ្យទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងវិស័យអប់រំនៅក្នុងដំណើរការកំណែទម្រង់វិស័យអប់រំ ដែលបច្ចុប្បន្ននេះកំពុងអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា។ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល មានអាសនៈចំនួន ៥ នៅក្នុងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ និងបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងវិស័យអប់រំ ទាំងនៅក្នុងការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) និងកម្មវិធីគាំទ្រវិស័យអប់រំក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ។

ដើម្បីចែកចាយការអនុវត្តល្អៗនៅថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG) ចុះថ្ងៃទី២៩ ខែមេសាឆ្នាំ ២០១១ ណែនាំឱ្យមន្ទីរអប់រំខេត្ត បង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិនៅក្នុងខេត្តនីមួយនៅទូទាំងប្រទេសកម្ពុជា។ គោលបំណងនៃក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ក្រោមជាតិ គឺដើម្បីលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីកៀរគរធនធាននិងបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អភិវឌ្ឍវិស័យអប់រំនៅក្នុងមូលដ្ឋានរបស់ខ្លួន។

នៅក្នុងសេចក្តីណែនាំនេះ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់អាសនៈជាអនុប្រធានក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ ដើម្បីតំណាងឱ្យសំឡេងសង្គមស៊ីវិលនៅក្នុងខេត្តនីមួយៗ ដែលមានន័យថាជួយសម្រួលដល់ការសហការគ្នារវាងរដ្ឋបាលមូលដ្ឋាន និងសង្គមស៊ីវិលដើម្បីសម្រេចបាននូវគោលបំណងនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣។ តំណាងនៃបណ្តាញថ្នាក់ខេត្តក្នុងវិស័យអប់រំត្រូវបានចាត់ទុកជាតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យអប់រំនៅក្នុងខេត្តនេះ ដូច្នេះអាចពាំនាំនូវសំឡេងនិងបញ្ហាប្រឈមនានារបស់អង្គការសង្គមស៊ីវិលមកដាក់លើតុពិភាក្សា ក្នុងគោលដៅស្វែងរកដំណោះស្រាយ។

ដោយទទួលស្គាល់ដោយក្រសួងអប់រំយុវជននិងកីឡាជាសំឡេងរបស់អង្គការមិនមែនរដ្ឋាភិបាលលើវិស័យអប់រំ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលមានតួនាទីនិងអាណត្តិក្នុងការគាំទ្រដល់សមាជិករបស់ខ្លួនជាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្សេងទៀតដែលធ្វើការក្នុងវិស័យអប់រំនៅប្រទេសកម្ពុជាដើម្បីរៀបចំនិងគាំទ្របណ្តាញអប់រំនៅក្នុងខេត្តនីមួយ។ ដូច្នេះចាប់តាំងពីឆ្នាំ២០១២មក អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល បានសម្របសម្រួលនិងគាំទ្រការបង្កើតក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត (P-ESWG) នៅទូទាំងប្រទេសកម្ពុជា។ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តចំនួន៥ ត្រូវបានបង្កើតឡើងរហូតដល់ឆ្នាំ២០១៣ បណ្តាញក្រុមការងារចំនួន១២ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ និងពេលបច្ចុប្បន្នមានចំនួន២៤នៅគ្រប់ខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា[2]។ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តទាំងអស់បានទទួលវគ្គបណ្តុះបណ្តាល ការកសាងសមត្ថភាព ការគាំទ្របច្ចេកទេស និងការប្រឹក្សាយោបល់ផ្សេងៗជាច្រើនពីអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដើម្បីបំពេញបេសកកម្មរបស់ខ្លួនក្នុងនាមជាតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្តនិងដើម្បីធ្វើការតស៊ូមតិឱ្យមានប្រសិទ្ធិភាពនៅថ្នាក់មូលដ្ឋានក្នុងន័យធ្វើឱ្យប្រជាជនកម្ពុជាទាំងអស់ទទួលបាន ការសិក្សាដូចៗគ្នា ទាន់ពេលវេលានិងប្រកបដោយគុណភាពខ្ពស់។

## ស្ថានភាពបច្ចុប្បន្ននៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តចាប់តាំងពីការបង្កើតដំបូង

បណ្តាញក្រុមការងារវិស័យអប់រំទាំង២៤ខេត្តក្រុង មានលក្ខណៈផ្សេងៗគ្នា ទាំងសមត្ថភាព ដំណើរការ និងសមិទ្ធផលសម្រេចបាន ដូចជាការរៀបចំការប្រជុំប្រចាំត្រីមាសទៀងទាត់ ការចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG) ការផ្តល់ធាតុចូលដល់មន្ទីរអប់រំលើការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំនេះ ការធ្វើការតស៊ូមតិដែលមានប្រសិទ្ធិភាព និងតំណាងឱ្យសំឡេងអង្គការមិនមែនរដ្ឋាភិបាលនានា។ ចាប់តាំងពីការបង្កើតបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលបានផ្តល់ការគាំទ្រនានា ផ្តល់យោបល់ និងការបណ្តុះបណ្តាលនៅក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះដោយមានការគាំទ្រពីអង្គការ UNICEF ។

[2] លើកលែងតែខេត្តប៉ៃលិន ដោយសារអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងខេត្តមានចំនួនតិច ពិបាកបង្កើតជាបណ្តាញក្រុមការងារមួយ ប៉ុន្តែមានការប្រជុំ និងចូលរួមជាមួយក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ។

ក្រុមការងារវិស័យអប់រំថ្នាក់ខេត្តមួយចំនួនបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាទៀងទាត់ ប៉ុន្តែនៅតែប្រឈមនឹងបញ្ហាក្នុងការសម្របសម្រួលកិច្ចប្រជុំ ជំរុញការចូលរួមរបស់សមាជិកទាំងអស់នៅក្នុងការជជែកពិភាក្សាគ្នាលើបញ្ហាប្រឈមដែលកើតឡើងនៅក្នុងខេត្តនីមួយៗ។ យើងសង្កេតឃើញថាការពិភាក្សាក្នុងកិច្ចប្រជុំប្រចាំត្រីមាសផ្តោតសំខាន់ទៅលើការចែករំលែកព័ត៌មានពីគម្រោង / កម្មវិធីអនុវត្តដោយអង្គការជាសមាជិកនីមួយៗ ហើយមិនសូវមានការជជែកពិភាក្សាច្រើនលើបញ្ហាសំខាន់ៗដែលខេត្តជួបប្រទេះនិងគួរត្រូវដោះស្រាយនោះទេ។ របៀបវារៈនៃកិច្ចប្រជុំនៅមានកម្រិត។ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តខ្លះទៀតជួបការលំបាកក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសឱ្យបានទៀងទាត់ ដោយសារថាសមាជិករបស់ខ្លួនជាប់រវល់ជាមួយភារកិច្ចស្នូលរបស់អង្គភាព។

## II. ទស្សនៈវិស័យ / បេសកកម្ម

### ទស្សនៈវិស័យ

ធ្វើការជាមួយគ្នាដើម្បីសម្រេចឱ្យបាននូវការអប់រំមួយប្រកបដោយគុណភាពខ្ពស់ បរិយាប័ន្នសម្រាប់ទាំងអស់គ្នា ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិនានាថា *"ការអប់រំគឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស"*។

### បេសកកម្ម

បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តក្លាយជាបណ្តាញដ៏រឹងមាំ មានប្រសិទ្ធភាពដែលជួយពង្រឹងការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការតាមដានសេវាអប់រំក្នុងតំបន់ និងក្នុងកិច្ចសន្ទនាគោលនយោបាយក្នុងវិស័យអប់រំ។

## III. ការបង្កើតបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត

### ១. រចនាសម្ព័ន្ធរបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត

បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត គឺជាបណ្តាញថ្នាក់ក្រោមជាតិនៃអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យអប់រំនៅក្នុងខេត្តនីមួយៗ ហើយមានគោលបំណងជំរុញរដ្ឋបាលមូលដ្ឋាន ព្រមទាំងការអនុវត្តគោលនយោបាយរដ្ឋាភិបាលថ្នាក់ជាតិ និងការអភិវឌ្ឍកម្មវិធីនានា ដើម្បីផ្តល់សេវាអប់រំដ៏ល្អប្រសើរនៅក្នុងប្រទេសកម្ពុជា តាមរយៈការចូលរួមដ៏រឹងមាំរបស់អង្គការសង្គមស៊ីវិលក្នុងការពិភាក្សាគោលនយោបាយនិងការតាមដានការអនុវត្តគោលនយោបាយ។

សមាសភាពបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តរួមមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាល ប្រធាន អនុប្រធាន និងលេខាដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត។




បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តនឹងបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំបណ្តាញ (ប្រធាន អនុប្រធាន និងលេខា) នៅចុងបញ្ចប់នៃអាណត្តិនីមួយៗ ហើយរៀបចំជាក្រុមការងារតូចៗបើចំបាច់ ដើម្បីដឹកនាំការស្វែងរកហិរញ្ញប្បទានគាំទ្រ និងអនុវត្តសកម្មភាពបន្ទាន់នានាជាមួយថ្នាក់ដឹកនាំបណ្តាញ។ ប្រធាននិងអនុប្រធានបណ្តាញការងារវិស័យអប់រំនឹងក្លាយជាតំណាងសំឡេងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិនៅក្នុងខេត្ត និងក្នុងវេទិកា ព្រឹត្តិការណ៍ផ្សេងៗនៃវិស័យអប់រំ ហើយមានសិទ្ធិក្នុងការចុះហត្ថលេខាលើឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងនាមសមាជិករបស់ខ្លួន។

## ២. និតិវិធីក្នុងការបង្កើតបណ្តាញក្រុមការងារ

ដើម្បីបង្កើតបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តមួយ ខាងក្រោមនេះជាជំហ៊ានផ្សេងៗដែលត្រូវអនុវត្តដើម្បីធ្វើឱ្យបណ្តាញលេចចេញរូបរាង៖

### ដំណើរការពិគ្រោះយោបល់

អង្គការមិនមែនរដ្ឋាភិបាលដែលមានគំនិតផ្តួចផ្តើមបង្កើតបណ្តាញក្រុមការងារវិស័យអប់រំ គួរតែស្វែងរកបញ្ជីនៃអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលមានវត្តមាននៅក្នុងខេត្តដែលកំពុងអនុវត្តគម្រោងអប់រំ និងកំណត់អង្គការសំខាន់ៗ ដើម្បីពិគ្រោះយោបល់គ្នាក្នុងការរៀបចំបង្កើតបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។ អង្គការមិនមែនរដ្ឋាភិបាលដែលមានគំនិតផ្តួចផ្តើមបង្កើតបណ្តាញក្រុមការងារវិស័យអប់រំ ក៏អាចស្វែងរកការគាំទ្រពីមន្ទីរអប់រំខេត្តដែរ ដើម្បីទទួលបានបញ្ជីនៃអង្គការមិនមែនរដ្ឋាភិបាលទាំងអស់នៅក្នុងខេត្ត ឬសុំការគាំទ្រពីអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)។

ដំណើរការពិគ្រោះយោបល់មានគោលបំណងទទួលយកធាតុចូលនានា គំនិតយោបល់និងយល់ពីសារៈសំខាន់នៃការបង្កើតបណ្តាញអង្គការមិនមែនរដ្ឋាភិបាលវិស័យអប់រំខេត្ត។

## ការរៀបចំកិច្ចប្រជុំលើកដំបូង

អង្គការមិនមែនរដ្ឋាភិបាលដែលមានគំនិតផ្តួចផ្តើមបង្កើតបណ្តាញក្រុមការងារវិស័យអប់រំគួរតែរៀបចំកិច្ចប្រជុំលើកដំបូងរបស់បណ្តាញដោយអញ្ជើញអង្គការទាំងអស់ដែលធ្វើការនៅក្នុងវិស័យអប់រំនៅក្នុងខេត្តឱ្យចូលរួម។ កិច្ចប្រជុំលើកដំបូងនេះនឹងជាឱកាស ដើម្បីពិភាក្សាអំពីក្របខ័ណ្ឌយោងរបស់បណ្តាញក្រុមការងារវិស័យអប់រំ កំណត់នីតិវិធីផ្សេងៗដើម្បីធានាថាបណ្តាញដំណើរការល្អ។

## លក្ខខណ្ឌសមាជិកភាព

សមាជិករបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរតែជាអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសហគមន៍ដែលកំពុងអនុវត្តគម្រោងអប់រំនៅក្នុងខេត្តដែលគេបោះទីតាំង។

## នីតិវិធីនៃការបោះឆ្នោត

សមាជិកនៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តដែលបានចូលរួមយ៉ាងហោចណាស់៥០%នៅកិច្ចប្រជុំរបស់បណ្តាញមានសិទ្ធិឈរឈ្មោះបោះឆ្នោតជា ប្រធាន អនុប្រធានឬលេខាធិការ។

## ការជ្រើសរើសបេក្ខជន

ការជ្រើសរើសបេក្ខភាពត្រូវតែប្រកាសដល់សមាជិកទាំងអស់ យ៉ាងហោចណាស់មួយខែមុនការបោះឆ្នោត។ ប្រសិនបើមានសមាជិកណាម្នាក់មានបំណងដាក់បេក្ខភាពសម្រាប់តួនាទីណាមួយនោះ គាត់គួរតែផ្ញើអ៊ីម៉ែល ដើម្បីបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួន ទៅដល់លេខាធិការនៃអាណត្តិបច្ចុប្បន្ននេះ។ បញ្ជីនៃបេក្ខជនឈរឈ្មោះត្រូវបញ្ជាក់ពីតួនាទីដែលគាត់ឈរឈ្មោះ ហើយបញ្ជីបេក្ខជននេះគួរតែដាក់ជូនសមាជិកទាំងអស់មួយសប្តាហ៍មុនពេលកិច្ចប្រជុំ (ការបោះឆ្នោត)។

## កូរ៉ុមនិងសុពលភាពនៃសន្លឹកឆ្នោត

ក្នុងថ្ងៃបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំបណ្តាញ ចាំបាច់ត្រូវមានកូរ៉ុមគ្រប់ចំនួន ដើម្បីធ្វើឱ្យលទ្ធផលការបោះឆ្នោតអាចយកជាការបាន។ យ៉ាងហោចណាស់ ៥០% បូកមួយនៃសមាជិកទាំងអស់ត្រូវតែមានវត្តមានក្នុងថ្ងៃបោះឆ្នោតនោះ។ សមាជិកដែលអវត្តមានក្នុងថ្ងៃបោះឆ្នោត ក៏អាចបោះឆ្នោតបានដោយផ្ញើសន្លឹកឆ្នោតខ្លួនទៅលេខា។ សមាជិកដែលអវត្តមានក៏អាចជ្រើសរើសសមាជិកម្នាក់ឱ្យបោះ

ឆ្នោតក្នុងនាមខ្លួន តាមរយៈលិខិតផ្ទេរសិទ្ធិ ។ សមាជិកម្នាក់ៗ(តំណាងឱ្យស្ថាបន័មួយ) មានសិទ្ធិក្នុងការបោះឆ្នោតមួយដង (សន្លឹកឆ្នោតមួយ) ។ បេក្ខជនដែលឈរឈ្មោះក៏អាចបោះឆ្នោតបានដែរ។

### លទ្ធផលនៃការបោះឆ្នោត

- បេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនជាងគេនឹងត្រូវបានជាប់ជាប្រធាន អនុប្រធាន និង លេខាធិការទៅតាមចំនួននៃសម្លេងឆ្នោតដែលទទួលបាន។
- បើសិនជាបេក្ខជនទទួលបានសម្លេងឆ្នោតដូចគ្នា អាទិភាពត្រូវបានផ្តល់ឱ្យទៅសមាជិកដែលមកប្រជុំទៀងទាត់ ឬសមាជិកជាស្ត្រីដើម្បីកាន់កាប់តំណែងជាប្រធាន។

### ការសុំលាលែងពីតំណែងរបស់ថ្នាក់ដឹកនាំបណ្តាញ

ប្រសិនបើប្រធាន អនុប្រធាន និងលេខាធិការសុំលាលែងចេញពីតំណែង ដោយសារមូលហេតុណាមួយក្នុងអំឡុងឆ្នាំប្រតិទិន ឬនៅក្នុងអណត្តិរបស់ខ្លួន ការបោះឆ្នោតនឹងត្រូវរៀបចំឡើងដើម្បីជំនួសតំណែងនេះ។

## ៣. អាណត្តិរបស់ប្រធាន អនុប្រធាន និងលេខាធិការ

ថ្នាក់ដឹកនាំបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តមានអណត្តិរយៈពេល២ ឆ្នាំ ចាប់ផ្តើមពីថ្ងៃជាប់ឆ្នោត និងអាចឈរឈ្មោះបោះឆ្នោតម្តងទៀត។ អណត្តិផ្សេងទៀតគួរតែត្រូវពិភាក្សានិងអនុម័តដោយសមាជិកភាគច្រើនរបស់បណ្តាញ។

## ៤. តួនាទីនិងការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន និងលេខាធិការ

### ប្រធាន - ប្រធានមានតួនាទីនិងការទទួលខុសត្រូវដូចខាងក្រោម៖

- ធ្វើជាប្រធានអង្គប្រជុំ
- សហការជាមួយអនុប្រធាននិងលេខាធិការដើម្បីរៀបចំការប្រជុំប្រចាំត្រីមាស និងសម្របសម្រួលកិច្ចប្រជុំ (រួមទាំងការអញ្ជើញសមាជិកឱ្យចូលរួម)
- ស្នើរបៀបវារៈសម្រាប់កិច្ចប្រជុំនីមួយៗ
- ដឹកនាំការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ កាលវិភាគនៃកិច្ចប្រជុំ និងសកម្មភាពផ្សេងទៀតដែលចាំបាច់។

- ចុះហត្ថលេខាលើឯកសារផ្លូវការនានា ដូចជាការចំណាយដែលរៀបចំដោយលេខាធិការ។
- សហការជាមួយអនុប្រធានដើម្បីបើកគណនីធនាគារ។
- ធ្វើជាអ្នកតំណាងនាំពាក្យផ្លូវការសម្រាប់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។
- តំណាងឱ្យបណ្តាញក្នុងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ។
- ដឹកនាំការតស៊ូមតិនៅគ្រប់វេទិកាទាំងអស់ និងគ្រប់កម្រិត។
- រៀបចំការបោះឆ្នោតជ្រើសរើសតំណែងនានានៃបណ្តាញនៅពេលតំណែងនោះនៅទំនេរ ឬអាណត្តិត្រូវបានបញ្ចប់។
- ដើរតួនាទីជាទីប្រឹក្សាសម្រាប់ប្រធាននៃបណ្តាញ នៅពេលដែលបញ្ចប់អាណត្តិ ដើម្បីធានានិរន្តរភាពរបស់បណ្តាញ។
- ធ្វើការស្វែងរកហិរញ្ញប្បទានទៅតាមតម្រូវការ។

**អនុប្រធាន - អនុប្រធានមានតួនាទីនិងការទទួលខុសត្រូវដូចខាងក្រោម៖**

- ធ្វើជាប្រធានអង្គប្រជុំនៅពេលប្រធានអវត្តមាន ឬតាមការស្នើសុំរបស់ប្រធាន។
- ផ្តល់ការគាំទ្រដល់ប្រធានក្នុងការបំពេញតួនាទីតស៊ូមតិ តាមការចាំបាច់។
- សម្របសម្រួលកិច្ចប្រជុំជាមួយប្រធាន។
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ និងសកម្មភាពតស៊ូមតិផ្សេងៗជាមួយប្រធាន។
- សហការជាមួយប្រធានដើម្បីបើកគណនីធនាគារ។

**- លេខាធិការ - លេខាធិការមានតួនាទីនិងការទទួលខុសត្រូវដូចខាងក្រោម៖**

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ និងកោះអញ្ជើញសមាជិកឱ្យចូលរួម។
- ត្រៀមរៀបចំកិច្ចប្រជុំ(ឯកសារសម្ភារៈផ្សេងៗ) ឱ្យរួចរាល់ មុនពេលកិច្ចប្រជុំចាប់ផ្តើម។
- រៀបចំរបាយការណ៍ ឬកំណត់ហេតុប្រជុំនិងប្រមូលផ្តុំយោបល់សមាជិកបញ្ចូលក្នុង របាយការណ៍ឬ កំណត់ហេតុ។
- ធានាថារបាយការណ៍ ឬ កំណត់ហេតុប្រជុំត្រូវបានចែកចាយដល់សមាជិកទាំងអស់មួយសប្តាហ៍ក្រោយការប្រជុំ។
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ។

### ៥. ការទទួលខុសត្រូវចម្បងរបស់សមាជិកបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត

សមាជិកបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តមានភារកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោម៖

- ចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ថ្នាក់ដឹកនាំបណ្តាញ។
- ចូលរួមចំណែកជាគំនិត / យោបល់ក្នុងពេលប្រជុំ។
- ចែករំលែកការអនុវត្តល្អៗ និងបទពិសោធន៍ពីការអនុវត្តគម្រោងរបស់ស្ថាប័នខ្លួន។
- ធ្វើបច្ចុប្បន្នភាពកម្មវិធី / គម្រោងដើម្បីធានាថាមិនមានសកម្មភាពជាន់គ្នា ឬមើលលទ្ធភាពក្នុងការធ្វើសុខដុមនីយកម្ម។
- បង់ថ្លៃសមាជិកភាពបើមានការកំណត់ឯកភាពដោយបណ្តាញក្រុមការងារ។

### ៦. ការទទួលស្គាល់ពីក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ

សេចក្តីណែនាំស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG) ចុះថ្ងៃទី២៩ ខែមេសាឆ្នាំ ២០១១ បានផ្តល់អាសនៈជាអនុប្រធានក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិដល់តំណាងឱ្យអង្គការសង្គមស៊ីវិលនៅក្នុងខេត្តនីមួយៗ។ ក្នុងន័យនេះ នៅពេលដែលថ្នាក់ដឹកនាំបណ្តាញក្រុមការងារវិស័យអប់រំត្រូវបានបោះឆ្នោតជាប់ ប្រធាននៃអណត្តិចាស់គួរសរសេរលិខិតជាផ្លូវការមួយ ក្នុងនាមបណ្តាញក្រុមការងារវិស័យអប់រំរបស់ខេត្ត ជូនដំណឹងដល់មន្ទីរអប់រំពីថ្នាក់ដឹកនាំថ្មីដែលជាប់ឆ្នោតនេះ។

## IV. ដំណើរការរបស់ក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត

ដើម្បីឱ្យបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តមានដំណើរការល្អ ចាំបាច់ត្រូវធ្វើសកម្មភាពសំខាន់មួយចំនួនដូចខាងក្រោម៖

### ១. រៀបចំលក្ខខណ្ឌយោង (TOR)

បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរតែតាក់តែង / ពិនិត្យមើលឡើងវិញនូវលក្ខខណ្ឌយោង (TOR) របស់បណ្តាញក្រុមការងាររបស់ខ្លួន ដែលមានការអធិប្បាយអំពីចក្ខុវិស័យ បេសកកម្ម គោលដៅ រចនាសម្ព័ន្ធ តួនាទីនិងភារកិច្ចរបស់ប្រធាន អនុប្រធាន លេខាធិការ និងសមាជិក និងវិធានការនៃការសម្រេចចិត្តផ្សេងៗទៀត។ សមាជិកបណ្តាញក្រុមការងារទាំងអស់ត្រូវយល់ឱ្យច្បាស់ពីលក្ខខណ្ឌ

យោង ហើយថ្នាក់ដឹកនាំត្រូវធ្វើយ៉ាងណាឱ្យសមាជិកនីមួយៗអនុវត្តលក្ខខណ្ឌយោងរបស់បណ្តាញ និងយល់ពីវិសាលភាពនៃការងាររបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។ លក្ខខណ្ឌយោងគួរតែត្រូវបានពិនិត្យឡើងវិញរៀងរាល់ពីរឆ្នាំម្តង។

## ២. រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

ដើម្បីជួយសម្រួលដល់ការតាក់តែងផែនការសកម្មភាពប្រចាំឆ្នាំ រួមមានសកម្មភាពដែលត្រូវធ្វើជាចាំបាច់ ត្រូវកំណត់អ្វីដែលបណ្តាញចង់សម្រេចឱ្យបាន លទ្ធផលរំពឹងទុក ។ បន្ទាប់មកសមាជិកនៃបណ្តាញក្រុមការងារត្រូវកំណត់ពីយុទ្ធសាស្ត្រដើម្បីសម្រេចលទ្ធផលរំពឹងទុកទាំងនេះ ហើយអ្នកដែលត្រូវចូលរួមអនុវត្តសកម្មភាព។

នៅក្នុងផែនការសកម្មភាពនេះ គួរតែរួមបញ្ចូលកាលវិភាគប្រជុំ ការប្រជុំជាមួយមន្ទីរអប់រំ និងការប្រជុំជាមួយក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG) និងធ្វើការរួមគ្នាជាមួយបណ្តាញអប់រំថ្នាក់ជាតិ (NEP)។ ផែនការសកម្មភាពប្រចាំឆ្នាំគួរតែត្រូវបានអនុម័តដោយសមាជិកទាំងអស់នៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសដំបូងនៃឆ្នាំ ហើយបន្ទាប់មកចែករំលែកដល់សមាជិកទាំងអស់[3]។

## ៣. រៀបចំការប្រជុំប្រចាំត្រីមាស

បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តត្រូវរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីធានាថាសមាជិកមានឱកាសជួបគ្នាជាទៀងទាត់ និងអាចចែករំលែកបទពិសោធន៍ផ្សេងៗ។ កាលបរិច្ឆេទនៃកិច្ចប្រជុំគួរតែត្រូវបានព្រមព្រៀងគ្នាជាមួយសមាជិកទាំងអស់ជាមុនសម្រាប់ពេញមួយឆ្នាំ។ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តក៏អាចរៀបចំការប្រជុំវិសាមញ្ញ ទៅតាមតម្រូវការជាក់ស្តែង និងបញ្ហាដែលអាចកើតឡើងនៅក្នុងខេត្តនីមួយ។

កិច្ចប្រជុំប្រចាំត្រីមាសគួរតែរៀបចំឡើង មុនកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG) ប្រសិនបើអាចធ្វើបាន ដើម្បីអាចឱ្យសមាជិកទាំងអស់លើកឡើងពីបញ្ហាប្រឈមរួម និងគិតពីយុទ្ធសាស្ត្រក្នុងការតស៊ូមតិជាមួយមន្ត្រីរដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ ឬលើកបញ្ហាប្រឈមទាំងនេះទៅថ្នាក់ជាតិ។

---

[3] សូមមើលទម្រង់ផែនការសកម្មភាពប្រចាំឆ្នាំនៅក្នុងឧបសម្ព័ន្ធ

## ៤. ការតស៊ូមតិ

បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរតែផ្តួចផ្តើមការងារតស៊ូមតិនៅកម្រិតផ្សេងៗ ដោយយោងលើព័ត៌មានជាក់លាក់ដែលប្រមូលបានដោយសមាជិករបស់បណ្តាញ។

### ការតស៊ូមតិនៅថ្នាក់ខេត្ត (P-JTWG)

នៅថ្នាក់ខេត្ត សមាជិកបណ្តាញក្រុមការងារវិស័យអប់រំគួរតែធ្វើការរួមគ្នាលើយុទ្ធសាស្ត្រតស៊ូមតិច្បាស់លាស់ដោយផ្អែកលើការរកឃើញជាក់លាក់ដើម្បីជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យអនុវត្តគោលនយោបាយថ្នាក់ជាតិនៃវិស័យអប់រំ ដូច្នេះចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាអប់រំ។

កំណត់បញ្ហាប្រឈមនានា ប្រមូលព័ត៌មាន និងតាមដានសេវាអប់រំ វិភាគព័ត៌មានទាំងអស់រួមគ្នាក្នុងពេលប្រជុំបណ្តាញក្រុមការងារវិស័យអប់រំ ធ្វើការសិក្សាស្រាវជ្រាវនៅកម្រិតមូលដ្ឋាននិងសហគមន៍ និងលើកបញ្ហាប្រឈមទាំងនោះទៅរដ្ឋបាលមូលដ្ឋាន ដើម្បីស្វែងរកដំណោះស្រាយ គឺជាភារកិច្ចចម្បងរបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។

កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG) គឺជាវេទិកាមួយដែលប្រធាននិងអនុប្រធានបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តអាចរកដំណោះស្រាយឆ្លើយតបនឹងបញ្ហាប្រឈមដែលកំពុងកើតមាននៅក្នុងខេត្តនីមួយៗ។ តំណាងបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរតែធ្វើការតស៊ូមតិ / លើកទឹកចិត្តឱ្យមន្ទីអប់រំខេត្តរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិឱ្យបានទៀងទាត់ និងអញ្ជើញចូលរួមប្រជុំឱ្យបានទៀងទាត់ដែរ។

### ចូលរួមក្នុងការតស៊ូមតិនៅថ្នាក់ជាតិជាមួយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលបានរៀបចំកិច្ចប្រជុំបណ្តាញអប់រំប្រចាំត្រីមាសនៅថ្នាក់ជាតិ ហើយបណ្តាញក្រុមការងារវិស័យអប់រំដែលតំណាងឱ្យបណ្តាញគ្រប់ខេត្តក្រុងទាំងអស់ត្រូវបានអញ្ជើញឱ្យចូលរួម។ ក្នុងពេលប្រជុំប្រចាំត្រីមាសនេះ រាល់ព័ត៌មានទាំងអស់ គោលនយោបាយអប់រំថ្មីៗ និន្នាការថ្មីៗ និងបច្ចុប្បន្នភាពទាក់ទងនឹងបណ្តាញក្រុមការងារត្រូវបានចែករំលែកដល់តំណាងបណ្តាញទាំងអស់ដើម្បីអាចបង្កើនចំណេះដឹងលើវិស័យអប់រំ។

តំណាងបណ្តាញក្រុមការងារវិស័យអប់រំត្រូវបានអញ្ជើញឱ្យចូលរួមចែករំលែកការអនុវត្តល្អៗ និងការរៀនសូត្រផ្សេងៗការងារតស៊ូមតិនៅក្នុងខេត្តនីមួយៗរបស់ខ្លួន។ កិច្ចប្រជុំថ្នាក់ជាតិនៃបណ្តាញក្រុមការងារវិស័យអប់រំនេះ គឺជាវេទិការមួយដែលបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តអាចលើកឡើង

ពីបញ្ហាប្រឈមរួមដែលកើតមាននៅក្នុងខេត្តរបស់ខ្លួន ហើយស្វែងរកយុទ្ធសាស្ត្រទូទៅសម្រាប់ជាការតស៊ូមតិរួមគ្នាឱ្យប្រសើជាងមុន។

## ៥. ការកសាងសមត្ថភាពសម្រាប់ថ្នាក់ដឹកនាំបណ្តាញ

សមាជិកបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរចែករំលែកចំណេះដឹង និងការអនុវត្តល្អៗនៃការអនុវត្តគម្រោងរបស់ស្ថាប័នរបស់ខ្លួនទៅដល់សមាជិកផ្សេងទៀតក្នុងពេលប្រជុំ។ ក្នុងពេលប្រជុំនីមួយៗ គួរតែគ្រោងរៀបចំការចែករំលែកអ្វីមួយ។

ប្រធាន និងអនុប្រធានបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តមានឱកាសជាច្រើនដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន តាមរយៈអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ដូចជាចូលរួមកិច្ចប្រជុំបណ្តាញក្រុមការងារវិស័យអប់រំ ប្រចាំត្រីមាសនៅថ្នាក់ជាតិ វគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងការតស៊ូមតិ ការសិក្សាស្រាវជ្រាវការប្រើប្រាស់ឧបករណ៍តាមដាន ទស្សនកិច្ចសិក្សាផ្លាស់ប្តូរអន្តរជាតិលើការតស៊ូមតិថ្នាក់មូលដ្ឋាន ព្រឹត្តការណ៍សិក្សារៀនសូត្រ ទស្សនកិច្ចសិក្សាគម្រោងរបស់អង្គការដៃគូ ឬការបណ្តុះបណ្តាលជាក់លាក់ផ្សេងទៀតតាមតម្រូវការរបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។

## ៦. ធានាឱ្យការទំនាក់ទំនងមានប្រសិទ្ធិភាព

ការទំនាក់ទំនងដែលមានប្រសិទ្ធិភាព គឺមានសារៈសំខាន់ណាស់សម្រាប់ពង្រឹងបណ្តាញដូចជាក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។ ការទំនាក់ទំនងមានគោលបំណងដើម្បីរក្សាទំនាក់ទំនងរវាងគ្នា ចែករំលែកព័ត៌មាន ការអនុវត្តល្អៗ និងកសាងទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធ ដូច្នេះអាចចូលរួមចំណែកក្នុងការពង្រឹងបណ្តាញក្រុមការងារឱ្យក្លាយទៅជាបណ្តាញដែលមានប្រសិទ្ធិភាព។ ប្រធាន អនុប្រធាន និងលេខាធិការ ត្រូវតែសកម្មខ្លាំងនៅក្នុងការទំនាក់ទំនងនេះ។ ការទំនាក់ទំនងមានពីរប្រភេទ៖

### ការទំនាក់ទំនងខាងក្នុង

ការទំនាក់ទំនងខាងក្នុងគួរតែធ្វើឡើងជាទៀងទាត់រវាងថ្នាក់ដឹកនាំបណ្តាញក្រុមការងារនិងសមាជិក។ មធ្យោបាយទំនាក់ទំនងផ្សេងៗគ្នាអាចនឹងត្រូវប្រើប្រាស់ ដូចជា**អ៊ីម៉ែល លិខិត ទូរស័ព្ទ បណ្តាញសង្គម** (ហ្វេសប៊ុក) ។

### ការទំនាក់ទំនងខាងក្រៅ

ថ្នាក់ដឹកនាំនៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរត្រូវបានលើកទឹកចិត្តដើម្បីធ្វើកាប្រាស្រ័យទាក់ទងយ៉ាងសកម្មជាមួយភាគីពាក់ព័ន្ធខាងក្រៅ ដូចជាមន្ទីរអប់រំ ការិយាល័យអប់រំស្រុក និងសមាជិកក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG)។ មធ្យោបាយទំនាក់ទំនងផ្សេងៗគ្នាអាចនឹងត្រូវប្រើប្រាស់ ដូចជាអ៊ីម៉ែល **លិខិត ទូរស័ព្ទ បណ្តាញសង្គម (ហ្វេសប៊ុក។ល។**

### ៧. ធ្វើរបាយការណ៍

ថ្នាក់ដឹកនាំនៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តត្រូវធ្វើរបាយការណ៍ប្រជុំនិងដាក់ជូនជាមួយរបាយការណ៍ហិរញ្ញវត្ថុ (ការចំណាយសម្រាប់កិច្ចប្រជុំនេះ)ឱ្យអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ក្រោយពីការប្រជុំប្រចាំត្រីមាសនីមួយៗ ឬភ្លាមៗបន្ទាប់ពីកិច្ចប្រជុំហើយ[4]។ របាយការណ៍នេះអាចធ្វើទៅតាមរយៈជនបង្គោលរបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលនៃខេត្តនីមួយៗ។

### ៨. ការទទួលស្គាល់ការងាររបស់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត

ថ្នាក់ដឹកនាំនៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តនឹងទទួលបានវិញ្ញាបនប័ត្រទទួលស្គាល់ការងារមួយ និងលិខិតណែនាំ[5] ក្រោយពីបានបញ្ចប់អាណត្តិពីរឆ្នាំរបស់ខ្លួន។ អង្គការភាពជាដៃគូអប់រំនៃអង្គការ ក្រៅរដ្ឋាភិបាលនឹងផ្តល់ជូនវិញ្ញាបនប័ត្រទទួលស្គាល់នេះ នៅពេលប្រជុំបណ្តាញក្រុមការងារវិស័យអប់រំ។

## V. វិធីសាស្ត្រខ្លះសម្រាប់ថ្នាក់ដឹកនាំ (ប្រធាន អនុប្រធាន និងលេខាធិការបណ្តាញ)

### ១. សម្របសម្រួលកិច្ចប្រជុំ

នៅក្នុងកិច្ចប្រជុំទាំងអស់ មានជំហ៊ានជាមូលដ្ឋានមួយចំនួនដើម្បីរៀបចំកិច្ចប្រជុំឱ្យទទួលបានជោគជ័យនិងមានប្រសិទ្ធិភាព ដែលការងារនេះទាមទារឱ្យមានការធ្វើផែនការ ការរៀបចំនិងការសម្របសម្រួល។

---

[4] គំរូរបាយការណ៍នេះមាននៅក្នុងឧបសម្ព័ន្ធ។

[5] letter of recommendation

អ្នកសម្របសម្រួលអាចជួយឱ្យកិច្ចប្រជុំទទួលបានជោគជ័យនិងមានការចូលរួម ដោយជំរុញសមាជិកទាំងអស់ឱ្យចូលរួមក្នុងការពិភាក្សានិងការសម្រេចចិត្ត។ បណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរសម្រេចចិត្តក្នុងចំណោមសមាជិកទាំងអស់ថាអ្នកណាជាអ្នកសម្របសម្រួលកិច្ចប្រជុំ ឬចែករំលែកភារកិច្ចសម្របសម្រួលនេះរវាងមនុស្សពីរនាក់ក្នុងកិច្ចប្រជុំមួយ ដើម្បីធ្វើឱ្យការសម្របសម្រួលកាន់តែប្រសើរឡើង។ បណ្ដាញក៏អាចសម្រេចចិត្តថាការងារសម្របសម្រួលត្រូវធ្វើឡើងដោយផ្លាស់ប្ដូរវេនគ្នាក្នុងចំណោមសមាជិកទាំងអស់ ដូច្នេះសមាជិកទាំងអស់អាចរៀនសូត្រពីជំនាញសម្របសម្រួលដែរ។

## ការធ្វើផែនការនិងការរៀបចំ

| មុនពេលប្រជុំ | ពេលប្រជុំ | ក្រោយពេលប្រជុំ |
|---|---|---|
| ▪ កំណត់គោលបំណងនៃកិច្ចប្រជុំ។<br>▪ រកទីកន្លែងប្រជុំដែលសមស្រប។<br>▪ រៀបចំរបៀបវារៈប្រជុំ។<br>▪ រៀបចំនិងផ្ញើលិខិតអញ្ជើញឱ្យបានមុនពេលប្រជុំដោយទុករយៈពេលមួយសមរម្យ។<br>▪ ត្រៀមប្រជុំ (សម្ភារៈ ឯកសារ អាហារសម្រន់)។ | ▪ រៀបចំកន្លែងអង្គុយ។<br>▪ ស្វាគមន៍អ្នកចូលរួម។<br>▪ បង្ហាញនិងព្រមព្រៀងគ្នាលើរបៀបវារៈ។<br>▪ ព្រមព្រៀងគ្នាលើពេលវេលាប្រជុំ។<br>▪ លើកយករបៀបវារៈមួយចំណុចម្ដងៗមកពិភាក្សា។<br>▪ កុំបណ្ដោយឱ្យមនុស្សដដែលនិយាយរហូតនៅក្នុងកិច្ចប្រជុំ។<br>▪ ជំរុញការចូលរួមរបស់សមាជិកទាំងអស់។<br>▪ កុំឱ្យកិច្ចប្រជុំនេះមានភាពតានតឹងពេក។<br>▪ បញ្ចប់កិច្ចប្រជុំឱ្យទាន់ពេលវេលាដែលបានកំណត់។<br>▪ កំណត់អ្នកធ្វើរបាយការណ៍។ | ▪ ផ្ញើរបាយការណ៍ប្រជុំទៅដល់សមាជិកគ្រប់ៗគ្នា ៣ថ្ងៃក្រោយពីការប្រជុំ។<br>▪ របាយការណ៍ប្រជុំគួរតែមានចំណុចពិភាក្សាគ្នា និងចំណុចត្រូវតាមដានសម្រាប់ការប្រជុំលើកក្រោយ។<br>▪ ផ្ញើសំណួរវាយតម្លៃការប្រជុំដល់អ្នកចូលរួមទាំងអស់។ ការវាយតម្លៃអាចជួយធ្វើឱ្យប្រសើរឡើងនូវការរៀបចំប្រជុំលើកក្រោយ។<br>▪ រក្សាទំនាក់ទំនងតាមរយៈអ៊ីម៉ែល ទូរស័ព្ទ និងហ្វេសប៊ុក។ |

### បញ្ហាប្រឈមមួយចំនួនដែលយើងសង្កេតឃើញក្នុងការសម្របសម្រួលកិច្ចប្រជុំនៅតាមបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ដែលបញ្ហាទាំងនេះ នាំឱ្យការប្រជុំមិនទទួលបានជោគជ័យ៖

**ការរៀបចំរបៀបវារៈ៖** មិនមានការចែកចាយរបៀបវារៈមួយឬពីរសប្ដាហ៍មុនពេលកិច្ចប្រជុំនោះទេ។ សមាជិកមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការផ្ដល់ជាធាតុចូល និងបន្ថែមអ្វីផ្សេងនៅក្នុងរបៀបវារៈទេ។

**កាលវិភាគជាន់គ្នា÷** ថ្ងៃប្រជុំបណ្ដាញក្រុមការងារត្រូវបានកំណត់នៅនាទីចុងក្រោយដែលអាចនាំឱ្យមានការចូលរួមតិចតួច ដោយសារសមាជិកជាន់កាលវិភាគជាមួយការងារដទៃទៀត។

**ខ្វះជំនាញក្នុងការសម្របសម្រួល៖** មានការចូលរួមតិចតួចពីសមាជិកទាំងអស់នៅក្នុងការពិភាក្សានិងការសម្រេចចិត្ត។ មនុស្សដដែលៗនិយាយគ្រប់ពេលទាំងអស់ក្នុងពេលប្រជុំ។ មិនមានការសម្រេចចិត្តណាមួយត្រូវបានធ្វើឡើង។

**ការធ្វើរបាយការណ៍៖** របាយការណ៍នៃការប្រជុំ គឺជាផ្នែកមួយលំបាកសម្រាប់បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត ពីព្រោះរបាយការណ៍តែងតែត្រូវបានធ្វើចេញទៅសមាជិកយឺតយ៉ាវ ឬរបាយការណ៍នៃការប្រជុំមិនមានគុណភាពគ្រប់គ្រាន់ (ការសម្រេចចិត្តនិងសកម្មភាពត្រូវតាមដាន)។

ថ្នាក់ដឹកនាំនៃបណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្តគួរពិចារណាអំពីបញ្ហានេះនិងដោះស្រាយឱ្យបានសមស្របមុននឹងរៀបចំការប្រជុំ។

- របៀបវារៈនៃកិច្ចប្រជុំគួរតែត្រូវបានស្នើឡើងដោយប្រធាននិងអនុប្រធាន ហើយចែកចាយដល់សមាជិកទាំងអស់យ៉ាងហោចណាស់១សប្តាហ៍មុនពេលប្រជុំ។
- ប្រធានឬអនុប្រធានអញ្ជើញសមាជិកឱ្យចូលរួមក្នុងការប្រជុំដោយបញ្ជាក់ពីពេលវេលានិងទីកន្លែងឱ្យបានច្បាស់លាស់។ ការអញ្ជើញគួរធ្វើឡើងតាមអ៊ីម៉ែល បន្ទាប់មកបញ្ជាក់តាមទូរស័ព្ទតាមក្រោយ។
- ទីកន្លែងប្រជុំអាចផ្លាស់ប្តូរគ្នា រវាងការិយាល័យអង្គការជាសមាជិករបស់បណ្តាញក្រុមការងារ។
- ការត្រៀមសម្ភារៈ ឯកសារប្រជុំ និងអាហារសម្រន់គួរតែត្រូវបានរៀបចំដោយលេខាធិការ។
- អ្នកសម្របសម្រួលកិច្ចប្រជុំគួរតែជ្រើសរើសក្នុងចំណោមសមាជិកបណ្តាញ និងផ្លាស់ប្តូរវេនគ្នា។
- ការប្រជុំមានគោលបំណងលើកឡើងពីបញ្ហាប្រឈមនានា និងរកយុទ្ធសាស្ត្រតស៊ូមតិដែលមានប្រសិទ្ធិភាពរួមគ្នា។
- សមាជិកបណ្តាញគួរតែឆ្លាស់គ្នាធ្វើរបាយការណ៍ប្រជុំ។

## ២. ការតម្រង់ទិសនិងការផ្ទេរតំណែងសម្រាប់ប្រធាន/អនុប្រធានថ្មី

នៅពេលដែលប្រធានបណ្តាញក្រុមការងារបញ្ចប់អាណត្តិរបស់ខ្លួន យើងតែងតែសង្កេតឃើញថាប្រធានថ្មីជួបការលំបាកក្នុងការបំពេញតួនាទីប្រតិបត្តិរបស់ខ្លួន និងសម្របសម្រួលបណ្តាញដោយសារគាត់ថ្មីសម្រាប់មុខតំណែងនេះ។ ជាអនុសាសន៍ បណ្តាញក្រុមការងារគួរតែទុករយៈពេលមួយកំណត់ដើម្បីត្រៀមផ្ទេរការងារនិងមុខងារផ្សេងៗឱ្យអ្នកកាន់តំណែងថ្មី ដើម្បីធានាឱ្យការងាររបស់បណ្តាញបន្តជានិច្ច និងធ្វើឱ្យបណ្តាញកាន់តែខ្លាំង។ ប្រធាននៃអាណត្តិចាស់គួរផ្ទេរឯកសារនានា ព័ត៌មាន និងទុកពេលវេលាគ្រប់គ្រាន់មួយដើម្បីប្រគល់ការងារ..

## ការណែនាំស្ដីពីការផ្ទេរការងារនិងមុខងារផ្សេងៗឱ្យប្រធាន និង / ឬអនុប្រធានថ្មី៖

### រៀបចំឯកសារផ្ទេរ

ប្រធាន/ អនុប្រធាននៃអាណត្តិចាស់គួររៀបចំឯកសារចាំបាច់ទាំងអស់មុនពេលបញ្ចប់អាណត្តិរបស់ខ្លួន។ ដើម្បីរៀបចំឯកសារចាំបាច់ ប្រធាន/ អនុប្រធានអាចពិភាក្សាជាមួយនឹងសមាជិកទាំងអស់ដើម្បីប្រមូលឯកសារនានា។ ឯកសារខាងក្រោមនេះគឺជាឯកសារចាំបាច់ដើម្បីប្រគល់ឱ្យប្រធាន/ អនុប្រធាននៃអាណត្តិថ្មី

- របាយការណ៍ប្រជុំប្រចាំត្រីមាសរបស់បណ្ដាញក្រុមការងារ
- របាយការណ៍ប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ
- របាយការណ៍និងវឌ្ឍនភាពហិរញ្ញវត្ថុរបស់បណ្ដាញក្រុមការងារ
- សៀវភៅណែនាំស្ដីពីការដឹកនាំបណ្ដាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត។
- លក្ខខណ្ឌយោងរបស់បណ្ដាញក្រុមការងារ
- បទប្បញ្ញត្តិនិងគោលការណ៍ណែនាំផ្សេងៗទាក់ទងទៅនឹងដំណើរការបណ្ដាញក្រុមការងារ
- អ៊ីម៉ែលនិងឯកសារទទន់ផ្សេងៗរបស់បណ្ដាញក្រុមការងារ

### រយៈពេលផ្ទេរតួនាទីផ្សេងៗ

នៅពេលដែលប្រធាន/អនុប្រធានថ្មីត្រូវបានបោះឆ្នោតជាប់ ប្រធាន/ អនុប្រធាននៃអាណត្តិចាស់គួរផ្ទេរ/បញ្ជូនរាល់ឯកសារទាំងអស់ទៅប្រធាន/អនុប្រធានថ្មី។ ប្រធាន/ អនុប្រធាននៃអាណត្តិចាស់គួរគាំទ្រនិងបង្ហាញពីតួនាទីនិងការទទួលខុសត្រូវផ្សេងៗនៃតំណែងនេះ និងសកម្មភាពផ្សេងៗដែលត្រូវអនុវត្ត។

### ការទទួលស្គាល់ថ្នាក់ដឹកនាំបណ្ដាញថ្មី

ថ្នាក់ដឹកនាំអាណត្តិចាស់ ប្រធាន / អនុប្រធានគួរសរសេរលិខិតជូនដំណឹងដល់មន្ទីរអប់រំ អំពីការបោះឆ្នោតជ្រើសរើសប្រធាននិងអនុប្រធានថ្មីរបស់បណ្ដាញក្រុមការងារវិស័យអប់រំ ហើយសូមឱ្យជំនួសឈ្មោះក្នុងបញ្ជីសមាជិកក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ (P-JTWG)។
ថ្នាក់ដឹកនាំអាណត្តិចាស់គួរជូនដំណឹងមកអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលពីថ្នាក់ដឹកនាំនៃអាណត្តិថ្មីនេះ។

### ការគាំទ្រថ្នាក់ដឹកនាំនៃអាណត្តិថ្មី

ថ្នាក់ដឹកនាំអាណត្តិចាស់គួរបន្តគាំទ្រនិងផ្ដល់ប្រឹក្សាដល់ថ្នាក់ដឹកនាំអាណត្តិថ្មី រយៈពេល៦ខែក្រោយពេលចប់អាណត្តិរបស់ខ្លួន។

# ឧបសម្ព័ន្ធនិងទម្រង់ផ្សេងៗ

# ទម្រង់ផែនការសកម្មភាពប្រចាំឆ្នាំ

| ឆ្នាំ២០១៧ | | | | |
|---|---|---|---|---|
| សកម្មភាព | ថវិកា | អ្នកទទួលខុសត្រូវ | កាលបរិច្ឆេទ | លទ្ធផលរំពឹងទុក |
| រៀបចំកិច្ចប្រជុំប្រចាំត្រីមាសទីមួយ | | | | |
| ចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ | | | | |
| រៀបចំកិច្ចប្រជុំប្រចាំត្រីមាសទីពីរ | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# ទម្រង់នៃលក្ខខណ្ឌយោង

| |
|---|
| លក្ខខណ្ឌយោង<br>បណ្តាញក្រុមការងារវិស័យអប់រំ ខេត្ត... |

សេចក្តីផ្តើម

ទស្សនៈវិស័យ / បេសកកម្ម

គោលបំណង

រចនាសម្ព័ន្ធរបស់ បណ្តាញក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត

បែបបទនៃការធ្វើការរបស់បណ្តាញ

ការទទួលខុសត្រូវចម្បងៗរបស់ប្រធាន អនុប្រធាននិងលេខាធិការ

ការទទួលខុសត្រូវចម្បងរបស់សមាជិកបណ្តាញ

ការប្រជុំប្រចាំត្រីមាស

សៀវភៅកម្រងព័ត៌មានរបស់អង្គការមិនមែនរដ្ឋាភិបាល

# លក្ខខណ្ឌយោង (ToR)
# បណ្តាញការងារវិស័យអប់រំ ខេត្តកំពង់ឆ្នាំង
(KEN/ESWG)

**១.គោលដៅ**

បណ្តាញការងារវិស័យអប់រំ ខេត្តកំពង់ឆ្នាំង (Kampong Chhnang Education Network Group (KEN) / Education Sector Working Group) មានគោលដៅដើម្បីពង្រឹងទំនាក់ទំនង និងកិច្ចសហការរវាងអង្គការមិនមែនរដ្ឋាបាលជាតិ អន្តរជាតិ ដែលអនុវត្តការងារក្នុងវិស័យអប់រំ និងដើម្បីកែលម្អការងារអប់រំក្នុងខេត្តកំពង់ឆ្នាំង ។

**២.គោលបំណង**

- ដើម្បីពង្រឹងទំនាក់ទំនងរវាងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ( Joint Technical Working Group (JTWG) ) នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលអនុវត្តការងារក្នុងវិស័យអប់រំ ។
- បង្កើតឱ្យមានវេទិកាពិគ្រោះយោបល់ និងចែករំលែកបទពិសោធន៍ដើម្បីដោះស្រាយបញ្ហារួមគ្នាស្តីពីវិស័យអប់រំនៅក្នុងខេត្ត ។
- សម្របសម្រួលក្នុងការរួមបញ្ចូលផែនការរបស់អង្គការដៃគូដែលអនុវត្តការងារវិស័យអប់រំទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ( Annual Operational Plan (AOP) ) របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ។
- លើកកម្ពស់កិច្ចសហការល្អ និងប្រកបដោយប្រសិទ្ធភាពរវាងមន្ទីរអប់រំ យុវជន និងកីឡា និងអង្គការដៃគូគាំទ្រវិស័យអប់រំ ដើម្បីអនុវត្តសកម្មភាពដែលបានដាក់ក្នុងផែនការប្រតិបត្តិ ប្រចាំឆ្នាំ (AOP) ឱ្យសម្រេចបានលទ្ធផលជោគជ័យ ក្នុងការគាំទ្រយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ។

**៣.រចនាសម្ព័ន្ធបណ្តាញការងារវិស័យអប់រំខេត្តកំពង់ឆ្នាំង**

- អង្គការ World Vision International-Cambodia (WVI-C) ប្រចាំខេត្ត ជាប្រធាន
- អង្គការ International Relief and Development (IRD) ប្រចាំខេត្ត ជាអនុប្រធាន
- អង្គការ Save the Children (SC) ជាអនុប្រធាន
- អង្គការ Society for Community Development in Cambodia (SOFDEC) ប្រចាំខេត្ត ជាលេខាធិការ

- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលអនុវត្តការងារវិស័យអប់រំក្នុងខេត្ត ជាសមាជិក (ព័ត៌មានលម្អិតមានក្នុងចំណុចទី៥ខាងក្រោម)

## ៤.តួនាទី និងភារកិច្ច

- បណ្តាញការងារវិស័យអប់រំខេត្តកំពង់ឆ្នាំង គឺជាស្ថាប័នឯករាជ្យ មិនរើសអើងចំពោះបុគ្គល ឬក្រុមណា មួយឡើយដូចជា ពណ៌សម្បុរ សាសនា ជាដើម ។
- ក្នុងពេលប្រជុំប្រធានបណ្តាញការងារវិស័យអប់រំមានឋានៈស្មើភាពដូចសមាជិកដែរ។ ប្រធានចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសវិស័យអប់រំក្នុងនាមតំណាងឱ្យ បណ្តាញការងារវិស័យអប់រំក្នុងខេត្ត ។
- ពេលដំណើរការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំប្រធានក្រុមក៏មានតួនាទីសំខាន់ជួយ សម្របសម្រួល រវាងមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងអង្គការដែលជាសមាជិកបណ្តាញការងារវិស័យអប់រំ ដើម្បីដាក់បញ្ចូលផែនការ សកម្មភាពការងារទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។
- ប្រធានឬអនុប្រធានបណ្តាញការងារវិស័យអប់រំមានភារកិច្ចជាប្រធានអង្គប្រជុំ នឹងត្រូវធ្វើ ឡើងជាលក្ខណៈប្តូរវេន ។
- ប្រធានឬ អនុប្រធានបណ្តាញការងារវិស័យអប់រំអាចអញ្ជើញតំណាងពីមន្ទីរអប់រំ ដែល មកពីការិយាល័យជំនាញពាក់ព័ន្ធ ចូលរួមប្រជុំពិភាក្សាជាមួយក្រុមក្នុងករណីចាំបាច់ ។
- តួនាទីលេខាអង្គប្រជុំនឹងត្រូវធ្វើឡើងជាលក្ខណៈប្តូរវេន ហើយនឹងត្រូវជ្រើសរើសចេញពី សមាជិកក្រុមការងារ ។ តួនាទីចម្បងរបស់លេខាគឺកត់ត្រាកំណត់ហេតុ ឬ របាយការណ៍ ប្រជុំ និងផ្ញើជូនសមាជិក្រុមការងារ ។
- រាល់ការប្រជុំមិនតម្រូវឱ្យមានការកំណត់ចំនួនសមាជិកចូលរួមឡើយ។ ប្រសិនបើប្រធាន ឬអនុប្រធានអវត្តមាន សមាជិកអាចសម្របសម្រួលដំណើរការប្រជុំបាន ។
- សមាជិកបណ្តាញការងារវិស័យអប់រំទាំងអស់ត្រូវ ចូលរួមប្រជុំឱ្យបានពេញលេញ និង ទៀងទាត់តាមការកំណត់ និងគាំទ្រគោលដៅ និងគោលបំណងរបស់ក្រុមការងារ ។
- សមាជិកក្រុមការងារមានតួនាទីចូលរួមក្នុងការរៀបចំរបៀបវារៈប្រជុំ អញ្ជើញសមាជិក ក្រុមការងារដទៃ និងមានការចូលរួមគំនិតយោបល់ក្នុងពេលប្រជុំ។

## ៥.អង្គការសមាជិកបណ្តាញការងារវិស័យអប់រំខេត្តកំពង់ឆ្នាំង

1. អង្គការ World Vision International-Cambodia (WVI-C)
2. អង្គការ International Relief and Development (IRD)
3. អង្គការ Save the Children (SC)

4. អង្គការ Society for Community Development in Cambodia (SOFDEC)

5. អង្គការ Kampuchean Action for Primary Education (KAPE)

6. អង្គការ World Food Program (WFP)

7. អង្គការ New Humanity (NH)

8. អង្គការ Life With Dignity (LWD)

9. អង្គការ Cambodia Trust (CT)

10. អង្គការ United Nations Children's Fund (UNICEF)

11. អង្គការ The Education For Development Fund Cambodia (EDF-Cambodia)

12. អង្គការ School Aid Japan (SAJ)

13. អង្គការ Operations Enfants du Cambodge (OEC)

14. សមាគមន៍ភ្នំនាងកង្រី Phom Neang Kangrei Association (PNKA)

និងអង្គការផ្សេងទៀតដែលអនុវត្តការងារក្នុងវិស័យអប់រំនៃខេត្តកំពង់ឆ្នាំង ទោះបីមិនទាន់ចូលជាសមាជិកក្រុមការងារវិស័យអប់រំក្នុងពេលនេះ ។

**៦.ការទទួលស្គាល់បណ្តាញការងារវិស័យអប់រំ**

ក្រុមការងារវិស័យអប់រំ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីលោក**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង** និងបុគ្គលិកអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង។ កិច្ចសហការល្អនេះនឹងជួយពង្រឹងទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ធ្វើការរួមគ្នា ដើម្បីសម្រេចគោលដៅក្នុងការកែលម្អការងារអប់រំក្នុងខេត្តកំពង់ឆ្នាំង ។

**៧.ការប្រជុំបណ្តាញការងារវិស័យអប់រំ**

បណ្តាញការងារវិស័យអប់រំនឹងប្រជុំ៤ដងក្នុងមួយឆ្នាំ (រៀងរាល់ត្រីមាស) ។ ការប្រជុំអាចធ្វើឡើងលើសពីនេះ តាមករណីចាំបាច់ ។

**៨.ទីកន្លែងប្រជុំ**

មិនមានការកំណត់ទីកន្លែងជាក់លាក់ណាមួយឡើយសម្រាប់ការប្រជុំ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកបណ្តាញការងារវិស័យអប់រំនឹងប្តូរវេនគ្នាក្នុងការរៀបចំទីកន្លែងប្រជុំ ។

**៩.ធនធានគាំទ្រក្នុងពេលប្រជុំបណ្ដាញការងារវិស័យអប់រំ**

ក្នុងករណីចាំបាច់តម្រូវឱ្យមានធនធានគាំទ្រការប្រជុំអង្គការដែលដឹកនាំការប្រជុំនឹងទទួលខុសត្រូវក្នុងការទិញសម្ភារនានា ។ ការចំណាយនឹងត្រូវបានទូទាត់ឡើងវិញ តាមរយៈ ប្រធាន អនុប្រធាន ឬលេខា ដែលគ្រប់គ្រងចាត់ចែងផ្នែកហិរញ្ញវត្ថុនៃបណ្ដាញការងារវិស័យអប់រំ ។

**១០. ថវិកាគាំទ្រក្នុងពេលប្រជុំបណ្ដាញការងារវិស័យអប់រំ**

បណ្ដាញការងារវិស័យអប់រំមានថវិកាចំនួន250ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ដែលគាំទ្រដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NGO Education Partnership (NEP)) ក្នុងការគាំទ្រសកម្មភាពប្រជុំ ។

លក្ខខណ្ឌយោងនេះនឹងត្រូវបានពិនិត្យនិងសម្រេចដោយសមាជិកបណ្ដាញការងារវិស័យអប់រំទាំងអស់ក្នុងខេត្តកំពង់ឆ្នាំង ។

កាលបរិច្ឆេទ: 30 វិច្ឆិកា ២០១៤

**ប្រធានបណ្ដាញការងារវិស័យអប់រំ**

**ខេត្តកំពង់ឆ្នាំង(ESWG/KEN)**

ហត្ថលេខា:..........................................

លោកស្រី **យូន រតនា**

កាលបរិច្ឆេទ: 06 ធ្នូ ឆ្នាំ ២០១៤

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

ហត្ថលេខា:..........................................

ពេជ្រ សំឫទ្ធ

## រចនាសម្ព័ន្ធរបស់ក្រុមការងារវិស័យអប់រំ

Education Sub–Working Group, Kampong Chhnang Education Network Group (ESWG/KEN)




## បញ្ជីឈ្មោះអង្គការសមាជិក

| ល.រ | ឈ្មោះ | ឋានៈ និងតួនាទី | អង្គភាព | លេខទូរស័ព្ទ | អាសយដ្ឋាន Email |
|---|---|---|---|---|---|
| 1 | អ្នកស្រី យួន រតនា | ប្រធាន | WVC | 017 44 7746 | rattana_youn@wvi.org |
| 2 | លោក ធូវី ហ្សាន់នី | អនុប្រធាន | IRD | 097 88 660 62 | hthovy@irdglobal.org |
| 3 | លោក ខេង មករា | អនុប្រធាន | SC | 092 286 786 | Meakara.Kheng@savethechildren.org |
| 4 | លោក ម៉ុត ពិសិដ្ឋ | លេខាធិការ | SOFDEC | 097 56 763 57 | pisethm@yahoo.com |
| 5 | លោក វ៉ារ សុវណ្ណា | សមាជិក | WFP | 012 78 72 56 | sovanna.var@wfp.org |
| 6 | លោក ស្រឿង ញាណ | សមាជិក | UNICEF | 077 67 13 90 | nsroeung@unicef.org |
| 7 | លោក ម៉ី សារុន | សមាជិក | LWD | 012 57 13 63 | sarun@lwd.org.kh |
| 8 | លោក សូ សុផៃ | សមាជិក | OEC | 017 66 24 25 | oec_kchh@yahoo.com |
| 9 | លោក ជឹង វាសនា | សមាជិក | NH | 012 32 44 04<br>069 34 20 80 | v.cheung@newhum.org |
| 10 | អ្នកស្រី សួន សុខា | សមាជិក | Cambodia Trust | 097 84 226 26<br>012 24 74 46 | cwdkpc@cambodiatrust.org.kh |
| 11 | លោក អ៊ុក សាម៉េត | សមាជិក | PNKA | 012 67 48 81 | uksametpnka@gmail.com |
| 12 | លោក ចេង ចាន់ឌី | សមាជិក | EDF_Cambodia | 012 81 23 37 | chandy_c@edfcam.org |
| 13 | កញ្ញា សុខ សម្ផស្ស | សមាជិក | School Aid Japan | 092 853 603 | soksamphoas010@yahoo.com |
| 14 | ហុង សុជាតិ | សមាជិក | KAPE | 012 32 52 42<br>010 75 68 23 | hong.socheat@kapekh.org |

# គោលនយោបាយសម្រាប់សមាជិក

**មាត្រា១៖** សមាជិករបស់បណ្តាញវិស័យអប់រំនៅខេត្តកំពង់ឆ្នាំងគឺជាអង្គការមិនមែនរដ្ឋាភិបាលដែលបំរើឱ្យវិស័យអប់រំដោយមិនស្វែងរកប្រាក់ចំណេញ ។ អង្គការទាំងនេះត្រូវប្រតិបត្តិការសម្មភាពរបស់ខ្លួននៅក្នុងខេត្តកំពង់ឆ្នាំង ។

**មាត្រា២៖** អង្គការដែលបានបំពេញលក្ខ័ណ្ឌគ្រប់គ្រាន់ ហើយក្លាយជាសមាជិករបស់ក្រុមគាំទ្រវិស័យអប់រំនៅក្នុងខេត្តកំពង់ឆ្នាំង មានសិទ្ធបោះឆ្នោត ឬ ឈរឈ្មោះ ឱ្យសមាជិកដទៃទៀតជ្រើសរើសធ្វើជាប្រធាន អនុប្រធាន ឬ លេខាធិការ ។

**មាត្រា៣៖** សមាជិករបស់ក្រុមគាំទ្រវិស័យអប់រំនៅក្នុងខេត្តកំពង់ឆ្នាំង ត្រូវតែចុះកិច្ចព្រមព្រៀងក្នុងការបំរើវិស័យអប់រំ ជាមួយក្រសួង ឬ មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង ។

**មាត្រា៤៖** សមាជិកទាំងអស់ត្រូវតែគាំទ្រដល់ផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំឆ្នាំ ២០១៤ ដល់ ២០១៨ *"ផ្តោតលើការពង្រឹងសមិទ្ធផលដែលមានកន្លងមក ការឈានទៅដល់ក្រុមជួបការលំបាក ការផ្តល់ការអប់រំប្រកបដោយគុណភាព និងភាពឆ្លើយតបសម្រាប់ការអភិវឌ្ឍប្រទេស"* ។

មាត្រា៥៖ សមាជិកទាំងអស់ត្រូវតែចូលរួមប្រជុំប្រចាំត្រីមាស និងកិច្ចប្រជុំផ្សេងៗទៀតដែលត្រូវបានអញ្ជើញ ។ តំណាងអង្គការដែលជាសមាជិក នោះត្រូវតែជាអ្នកដែលមានទំនួលខុសត្រូវទាក់ទងនឹងវិស័យអប់រំ ។

**មាត្រា៦៖** សមាជិកទាំងអស់ត្រូវតែជួយផ្តល់ ឯកសារផ្សេងៗដល់ប្រធាន អនុប្រធាន ឬលេខា ក្នុងគោលដៅ ដើម្បីរៀបចំរបាយការណ៍នានាដែលតម្រូវដោយក្រសួងអប់រំ យុវជននិងកីឡា ឬ មន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ឆ្នាំង ។

**មាត្រា៧៖** ប្រធាន អនុប្រធាន ឬលេខា មានអណត្តិរបស់ខ្លួនរយៈពេល៣ឆ្នាំ ដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសមាជិក ។ ប៉ុន្តែក្នុងករណីមិនប្រក្រតីមួចចំនួន ប្រធាន អនុប្រធាន ឬ លេខាធិការ ត្រូវតែរំលាយចេញ និងធ្វើការបោះឆ្នោតសារជាថ្មីក្នុងរយៈពេល បីខែ ។ សមាជិកនីមួយៗមានសិទ្ធិឈរឈ្មោះចំនួនពីរអណត្តិ ។

**មាត្រា៨៖** ប្រធាន អនុប្រធាន ឬលេខាធិការ ជាអ្នកតំណាងឱ្យអង្គការជាសមាជិកក្នុងការដោះស្រាយបញ្ហាផ្សេងៗ និងមានតួនាទី និងភារកិច្ច ដូចមានចែងក្នុង***លក្ខខណ្ឌយោង (ToR) នៃបណ្តាញការងារវិស័យអប់រំ ខេត្តកំពង់ឆ្នាំង***។

**មាត្រា៩៖** សមាជិកទាំងអស់ត្រូវតែរាយការណ៍ រាល់បញ្ហាដែលទាក់ទងនឹងវិស័យអប់រំ ដែលខ្លួនកំពុងអនុវត្តក្នុងកម្រោងរបស់ខ្លួន ក្នុងកំឡុងពេលប្រជុំប្រចាំត្រីមាសនីមួយៗ ទៅកាន់ប្រធាន អនុប្រធាន ឬលេខាធិការ ។

**មាត្រា១០៖** ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិនឹងមិនដោះស្រាយបញ្ហាប្រឈមរបស់សមាជិកបណ្តាញការងារវិស័យអប់រំ បើសិនសមាជិកបណ្តាញមិនរាយការណ៍តាមរយៈប្រធាន អនុប្រធាន ឬលេខាធិការរបស់បណ្តាញការងារវិស័យអប់រំ ។

**មាត្រា១១៖** សមាជិកដែលមិនបានចូលរួមប្រជុំ ឬមិនមានតំណាងរបស់ខ្លួនចូលរួមប្រជុំ **ចំនួនបីដង** នឹងត្រូវលប់ឈ្មោះចេញពីបញ្ជីសមាជិកក្នុងមួយឆ្នាំ ។

**មាត្រា១២៖** សមាជិកដែលត្រូវបានលប់ឈ្មោះចេញពីបញ្ជីសមាជិក នឹងមិនត្រូវបានគាំទ្រការងារអប់រំដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំងឡើយ ។

**មាត្រា១៣៖** ប្រធាន អនុប្រធាន ឬលេខាធិការដែលសុំលាលែងពីតំណែងរបស់ខ្លួនត្រូវមានសេចក្តីស្នើសុំជាលាយលក្ខណ៍អក្សររយៈពេល ២ខែជាមុន ។

កាលបរិច្ឆេទ: 30 វិច្ឆិកា 2016

**ប្រធានបណ្តាញការងារវិស័យអប់រំ**

**ខេត្តកំពង់ឆ្នាំង (ESWG/KEN)**

ហត្ថលេខា:..............................

លោកស្រី **យួន រតនា**

កាលបរិច្ឆេទ: 06 ធ្នូ ឆ្នាំ 2016

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

ហត្ថលេខា:..............................

ពេជ្រ សំបូរ

# ទម្រង់នៃរបៀបវារៈ

## របៀបវារៈកិច្ចប្រជុំប្រចាំត្រីមាសទី១

កាលបរិច្ឆេទ : ...........

ពេលវេលា: ...........

ទីកន្លែង: ...........

គោលបំណង:

- ចែករំលែកបញ្ហាប្រឈមនៅក្នុងខេត្ត
- ចែករំលែកពីបទពិសោធន៍

លទ្ធផលរំពឹងទុក:

- បញ្ហាអទិភាពនៅក្នុងខេត្តត្រូវបានកំណត់

| ម៉ោង | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| | ចុះឈ្មោះ | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

## ទម្រង់នៃរបាយការណ៍ ឬកំណត់ហេតុ

របាយការណ៍នៃកិច្ចប្រជុំប្រចាំត្រីមាស

៙៙៙៙៙

កាលបរិច្ឆេទ : ...........

ទីកន្លែង: ...........

អ្នកចូលរួម: ...........

| របៀបវារៈ | ចំណុចពិភាក្សា/សេចក្ដីសម្រេច | សកម្មភាពត្រូវតាមដាន |
|---|---|---|
| | | |
| | | |

រៀបចំដោយ:
ឈ្មោះ:
អ្នកធ្វើរបាយការណ៍:
ថ្ងៃ:...... / .........../ ..........

អនុម័តដោយ:
ឈ្មោះ:
ប្រធាន:
ថ្ងៃ:...... / .........../ ..........

# បញ្ជីសមាជិក

| ល | ឈ្មោះ | តួនាទី | ឈ្មោះស្ថាប័ន | អក្សរកាត់ | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# បញ្ជីវត្តមាន

ថ្ងៃប្រជុំ: ……

| ល | ឈ្មោះ | តួនាទី | ភេទ | ឈ្មោះស្ថាប័ន | លេខទូរស័ព្ទ | អ៊ីម៉ែល | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# សេចក្តីណែនាំស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ: ០៤ អយក សណន

មន្ទីរអប់រំខេត្តកំពង់ធំ
ចូល លេខ: 634
ថ្ងៃទី 03.05.11 ម៉ោង........
បញ្ជូន........

V.
03.5.011

## សេចក្តីណែនាំ
## ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ

ការបង្កើតក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ គឺផ្អែកលើសេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីខែតុលា ឆ្នាំ ២០១០ និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៨ ស.ស.រ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១០។

ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ គឺជាអង្គភាពសម្រាប់ផ្តល់ការគាំទ្រ និងកិច្ចសម្របសម្រួល ហើយក៏មិនមែនបង្កើតឡើងដើម្បីធ្វើការជំនួស ឬមានមុខងារជាន់គ្នាជាមួយនឹងក្រសួង និងស្ថាប័នសាមីឡើយ។ ក្រុមការងារបច្ចេកទេសចម្រុះ ត្រូវមានគណនេយ្យភាពចំពោះក្រសួង និងស្ថាប័នរបស់ខ្លួន ។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្តទាំងអស់ ឲ្យបង្កើតក្រុមការងារបច្ចេកទេសរបស់ខ្លួន និងដាក់ឲ្យដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

### ១. គោលបំណង

គោលបំណងរួមនៃក្រុមការងារបច្ចេកទេសចម្រុះរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឬហៅថាក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ក្រោមជាតិ គឺសំដៅលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក៏ដូចជាអ្នកដែលមានការពាក់ព័ន្ធទាំងអស់ ដើម្បីកៀរគរធនធាន និងបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អភិវឌ្ឍវិស័យអប់រំនៅក្នុងមូលដ្ឋានរៀងៗខ្លួន ។

### ២. សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ

សមាសភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំនៅថ្នាក់ក្រោមជាតិ រួមមានមន្ត្រីជាតំណាងមន្ទីរ ស្ថាប័នរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍ និងតំណាងសង្គមស៊ីវិលដែលមានពាក់ព័ន្ធនឹងវិស័យអប់រំនៅតាមរាជធានី ខេត្ត ។ ដើម្បីធានាបានប្រសិទ្ធភាពការងារ ក្រុមការងារនេះ គប្បីដឹកនាំ

ដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងមានប្រធានក្រុមការងាររបស់ដៃគូអភិវឌ្ឍជាអនុប្រធានម្នាក់ក្នុងចំណោមអនុប្រធានដទៃទៀត ។ ចំពោះចំនួនសមាជិក ក៏គប្បីកំណត់ក្នុងបរិមាណមួយសមស្របងាយស្រួលគ្រប់គ្រង និងដឹកនាំការប្រជុំប្រកបដោយប្រសិទ្ធភាពខ្ពស់។ សមាសភាពខាងក្រោមជាគំរូមួយ សម្រាប់មន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្ត ធ្វើការពិចារណាជាមូលដ្ឋានដើម្បីបង្កើតក្រុមការងាររបស់ខ្លួន៖

១. ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ........................................................ប្រធាន
២. អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា (ទទួលបន្ទុកការងារផែនការ)...................... អនុប្រធាន
៣. ប្រធានក្រុមការងាររបស់ដៃគូអភិវឌ្ឍវិស័យអប់រំ ..................................................អនុប្រធាន
៤. ប្រធានឬអនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .................................................. អនុប្រធាន
៥. ប្រធានឬអនុប្រធានខុទ្ទកាល័យសាលារាជធានី ខេត្ត ........................................... សមាជិក
៦. ប្រធានឬអនុប្រធានមន្ទីរផែនការ ......................................................................... សមាជិក
៧.ប្រធានឬអនុប្រធានមន្ទីរកិច្ចការនារី ..................................................................... សមាជិក
៨. ប្រធានឬអនុប្រធានមន្ទីរសុខាភិបាល ................................................................ សមាជិក
៩. ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ......................................................... សមាជិក
១០. ប្រធានឬតំណាងក្រុមភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ ..... សមាជិក
១១. ប្រធានឬតំណាងអង្គការអន្តរជាតិដែលកំពុងគាំទ្រវិស័យអប់រំ ............................ សមាជិក
១២. ប្រធានឬអនុប្រធានការិយាល័យគណនេយ្យ ..........................................................សមាជិក
១៣. ប្រធានឬអនុប្រធានការិយាល័យបុគ្គលិក ...............................................................សមាជិក
១៤. ប្រធានការិយាល័យផែនការ (ផែនការគណនេយ្យនិងសម្ភារៈ) .......................សមាជិកអចិន្ត្រៃយ៍
១៥. អនុប្រធានការិយាល័យផែនការ (ផែនការគណនេយ្យនិងសម្ភារៈ) ............... លេខាធិការ

ក្រៅពីសមាជិកដែលបានចាត់តាំងខាងលើ ប្រធានក្រុមការងារ មានសិទ្ធអញ្ជើញអ្នកដែលមានការពាក់ព័ន្ធនានា មកចូលរួមធ្វើបទបង្ហាញ ឬរាយការណ៍លើប្រធានបទជាក់ស្តែង តាមការឯកភាពគ្នា និងតាមការចាំបាច់របស់ក្រុមការងារ ។

### ៣. ភារកិច្ចនិងការទទួលខុសត្រូវ

ក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់ក្រោមជាតិ ត្រូវបង្កើតលេខាធិការដ្ឋានមួយដោយទទួលបានការគាំទ្រជាធនធានចាំបាច់នានា ដើម្បីជួយសម្របសម្រួលដំណើរការរបស់ខ្លួន ។ តួនាទីរបស់លេខាធិការដ្ឋានរួមមាន ការសម្របសម្រួលកិច្ចប្រជុំ ការចែកឯកសារ របាយការណ៍ និងការរៀបចំកំណត់ហេតុប្រជុំនីមួយៗ ជាដើម ។

ក្រុមការងារបច្ចេកទេសក្នុងវិស័យអប់រំថ្នាក់ក្រោមជាតិ ត្រូវអនុវត្តភារកិច្ចយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាពដោយផ្អែកលើកម្មវិធីការងារដែលបានគ្រោងទុក ដើម្បីរួមចំណែកសម្រេចបានៈ

(i). ចំណុចដៅនានារបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣

(ii). ការពិនិត្យតាមដាននិង ការពិនិត្យឡើងវិញការបំពេញការងារវិស័យអប់រំ

(iii). ការប្រមូល និងគ្រប់គ្រងទិន្នន័យជំនួយអភិវឌ្ឍផ្លូវការ ជាពិសេសគម្រោងសកម្មភាពកំពុងអនុវត្តដោយដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា

(iv) ការពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាប្រចាំឆ្នាំ និងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំជាដើម

(v) ការកំណត់សកម្មភាពពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូ

(vi) ការធ្វើរបាយការណ៍រួមស្តីពីវឌ្ឍនភាពសូចនាករសំខាន់ចាំបាច់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៩- ២០១៣

(vii) កិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសវិស័យអប់រំថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅរៀងរាល់បីខែម្តង ឬអាចរៀបចំប្រជុំផ្សេងទៀតតាមការចាំបាច់

(viii) ការកំណត់របៀបវារៈប្រជុំឲ្យច្បាស់លាស់ តាមផែនការការងារប្រចាំឆ្នាំ និងសូចនាករពិនិត្យតាមដាន ក្នុងកិច្ចប្រជុំនីមួយៗ នឹងបន្តកែលម្អឱ្យស៊ីចង្វាក់គ្នា ។

(ix) ប្រធានក្រុមការងារ ឬអ្នកតំណាងប្រធានក្រុមការងារ និងអ្នកដឹកនាំសម្របសម្រួលត្រូវធ្វើទំនាក់ទំនងគ្នាជាប្រចាំពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយ ដើម្បីតាមដានសកម្មភាពដែលបានឯកភាពហើយ។

លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានភារកិច្ចចាត់ចែងអនុវត្តសេចក្តីណែនាំនេះឱ្យទទួលបានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាព។

**រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១១**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល</u>

-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-អង្គភាពពាក់ព័ន្ធ

-សាលារាជធានី-ខេត្ត

*«ដើម្បីជូនជ្រាបជាព័ត៌មាន»*

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

*«ដើម្បីអនុវត្ត»*

-ឯកសារ-កាលប្បវត្តិ

3

